**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ : ០៥៦/២១ សរណ

ថ្ងៃ ៧៤ ១១ រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបន្ថែមទីតាំងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនកុមារ និងយុវវ័យ ដែលមានអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ក្នុងភូមិសាស្ត្រខណ្ឌ៧មករា នៃរាជធានីភ្នំពេញ

**រដ្ឋបាលរាជធានីភ្នំពេញ** មានកិត្តិយសសូមជម្រាបជូនបងប្អូនប្រជាពលរដ្ឋដែលជាមាតាបិតា និងអាណាព្យាបាល ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា កន្លងមករដ្ឋបាលរាជធានីភ្នំពេញធ្លាប់បានជូនដំណឹងអំពីយុទ្ធនាការចាក់វ៉ាក់សាំង សម្រាប់កុមារ និងយុវវ័យដែលមានអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ នៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក សរុបចំនួន ៣៩ទីតាំង នៅក្នុងភូមិសាស្ត្រខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញចាប់ពីថ្ងៃទី០១ រហូតដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ សម្រាប់ជុំសទី១។ បន្ទាប់ពីការប្រកាសបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់កុមារ និងយុវវ័យដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងក្រោយពីទទួលបានការជូនដំណឹងរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ រដ្ឋបាលរាជធានីភ្នំពេញ សង្កេតឃើញថាមានមាតាបិតា និងអាណាព្យាបាលជាច្រើនបាននាំបុត្រធីតា និងសាច់ញាតិរបស់ខ្លួនមកទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩មានចំនួនយ៉ាងច្រើនកុះករ ដែលកាយវិការនេះបានបង្ហាញឱ្យឃើញពីការរួមចំណែករបស់ប្រជាពលរដ្ឋក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសការចាក់វ៉ាក់សាំងដើម្បីបង្កើតភាពស៊ាំក្នុងសហគមន៍។ ដើម្បីជំរុញឱ្យការចាក់វ៉ាក់សាំងប្រព្រឹត្តទៅបានលឿន និងឆាប់រហ័សស្របតាមផែនការកំណត់ រដ្ឋបាលរាជធានីភ្នំពេញ អនុញ្ញាតជូន មន្ទីរសម្រាកព្យាបាល អូឡាំព្យា មេឌីខល ដែលបានស្ម័គ្រចិត្តចូលរួមផ្តល់សេវាចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់កុមារ និងយុវវ័យដែលមានអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដោយឥតគិតថ្លៃ។ អាស្រ័យហេតុនេះ សូមមាតាបិតា និងអាណាព្យាបាល ដែលមានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងខណ្ឌ៧មករា អញ្ជើញយកបុត្រធីតា និងសាច់ញាតិរបស់ខ្លួនទៅទទួលយកសេវាចាក់វ៉ាក់សាំងដោយឥតគិតថ្លៃនៅ មន្ទីរសម្រាកព្យាបាល អូឡាំព្យា មេឌីខល ដែលមានទីតាំងនៅអូឡាំព្យាស៊ីធី អគារស៊ី៥ ផ្លូវ១៦១ សង្កាត់វាលវង់ ខណ្ឌ៧មករា។

ទន្ទឹមនឹងនេះ **រដ្ឋបាលរាជធានីភ្នំពេញ** សូមអំពាវនាវ និងលើកទឹកចិត្តដល់មន្ទីរសម្រាកព្យាបាលឯកជនទាំងអស់ ដែលមានបំណងចង់ចូលរួមផ្តល់សេវាចាក់វ៉ាក់សាំងដើម្បីការពារខឿនសុខុមាលភាពសាធារណៈ ដោយឥតគិតថ្លៃជូនដល់កុមារ និងយុវវ័យដែលមានអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ អាចធ្វើការស្នើសុំដោយភ្ជាប់មកជាមួយនូវឯកសារគតិយុត្ត និងលិខិតបញ្ជាក់ផ្សេងៗចេញដោយស្ថាប័នមានសមត្ថកិច្ច មក រដ្ឋបាលរាជធានីភ្នំពេញ ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យសម្រេចជូន។

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ជាថ្មីម្តងទៀត **រដ្ឋបាលរាជធានីភ្នំពេញ** សូមក្រើនរំលឹកដល់មាតាបិតា និងអាណាព្យាបាលដែលត្រូវនាំបុត្រធីតា ឬសាច់ញាតិ មកទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ត្រូវប្រកាន់ខ្ជាប់ឱ្យបានជាដាច់ខាតនូវការរក្សាគម្លាតសុវត្ថិភាព ការពាក់ម៉ាស តម្រង់ជួរ ចៀសវាងការឈរប្រជ្រៀតគ្នា កៀកគ្នា ណែនណាន់តាន់តាប់ ហើយត្រូវប្រកាន់ខ្ជាប់ការចូលរួមអនុវត្តនូវវិធានការសុខាភិបាល និងវិធានការ "**៣ ការពារ និង ៣ កុំ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឈរលើស្មារតីស្រឡាញ់ជាតិ សហគមន៍ អាយុជីវិតផ្ទាល់ខ្លួននិងក្រុមគ្រួសារក្នុងឆន្ទៈរួមគ្នាជាធ្លុងមួយ ដើម្បីឈានទៅលុបបំបាត់ និងកាត់ផ្តាច់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុង "ព្រឹត្តិការណ៍សហគមន៍ **២០កុម្ភៈ ២០២១**" ឱ្យបានឆាប់នាពេលខាងមុខនេះ។

ខ្លឹមសារដូចបានជម្រាបជូនខាងលើនេះ សូមបងប្អូនប្រជាពលរដ្ឋក្នុងភូមិសាស្ត្ររាជធានីភ្នំពេញដែលជាមាតាបិតា និងអាណាព្យាបាល ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- គ.វ.ក-១៩

"ដើម្បីជូនជ្រាបព័ត៌មាន"
- រដ្ឋបាលខណ្ឌ៧មករា
- មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ

"ដើម្បីមុខការ"
- គ្រប់ប្រព័ន្ធឃោសនា

"ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ